# អំណោយទានដ៏ទេវភាពនៃការប្រែចិត្ត

*ដោយអែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន*
*នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់*

ព្រះគម្ពីរមរមនរួមមានដំណើររឿងរបស់បុរសម្នាក់ឈ្មោះ នីហ៊រ ។ វាងាយនឹងយល់ពីមូលហេតុដែលមរមនបានគិតថា ជាការសំខាន់ក្នុងការបញ្ចូលអ្វីមួយពីបុរសនេះ និងឥទ្ធិពលដ៏យូរអង្វែងនៃគោលលទ្ធិរបស់គាត់ ពេលមរមនសង្ខេបបញ្ជីប្រវត្តិរយៈពេលមួយពាន់ឆ្នាំរបស់នីហ្វៃ ។ មរមនព្យាយាមព្រមានយើង ដោយដឹងថា ទស្សនៈវិជ្ជានេះនឹងត្រូវបានបង្រៀនម្តងទៀត ក្នុងជំនាន់យើង ។

នីហ៊រ ត្រូវបាននិយាយដល់ ប្រហែលជា 90 ឆ្នាំ មុនកំណើតព្រះគ្រីស្ទ ។ គាត់បានបង្រៀនថា « មនុស្សលោកទាំងអស់ត្រូវតែបានសង្គ្រោះ នៅថ្ងៃចុងក្រោយបង្អស់ ...ត្បិតព្រះអម្ចាស់ទ្រង់បានបង្កើតមនុស្សទាំងអស់ ហើយបានប្រោសលោះមនុស្សទាំងអស់ផង ហើយនៅទីបញ្ចប់ មនុស្សទាំងអស់នឹងមានជីវិតដ៏នៅអស់កល្បជានិច្ច » ( អាលម៉ា 1:4 ) ។

ប្រហែល 15 ឆ្នាំ ក្រោយមក កូរីហ៊រ បានមកក្នុងចំណោមពួកសាសន៍នីហ្វៃ ដោយប្រកាសផ្សាយគោលលទ្ធិរបស់នីហ៊រ ។ ព្រះគម្ពីរមរមនកត់ត្រាថា « វាជាអ្នកទទឹងនឹងព្រះគ្រីស្ទ ព្រោះវាបានចាប់ផ្តើមបង្រៀនប្រជាជនទាស់នឹងពាក្យព្យាករណ៍ទាំងឡាយ... អំពីការយាងមកនៃព្រះគ្រីស្ទ » ( អាលម៉ា 30:6 ) ។ ការបង្រៀនរបស់កូរីហ៊រគឺថា « ពុំអាចមានដង្វាយធួនដែលធ្វើឡើង ដើម្បីធ្វើឲ្យធួននឹងអំពើបាបទាំងឡាយនៃមនុស្សទេ ប៉ុន្តែមនុស្សគ្រប់រូបរស់នៅក្នុងជីវិតនេះ ស្របតាមការរៀបចំនៃខ្លួន ហេតុដូច្នេះហើយ មនុស្សគ្រប់រូបបានចម្រើនឡើង ស្របតាមការឈ្លាសវៃរបស់ខ្លួន ហើយមនុស្សគ្រប់រូបដណ្តើមយកស្របតាមកម្លាំងរបស់ខ្លួន ហើយអ្វីៗក៏ដោយដែលមនុស្សបានប្រព្រឹត្ត គឺគ្មានទោសសោះ » ( អាលម៉ា 30:17 ) ។ ព្យាការីក្លែងក្លាយទាំងនេះ និងអ្នកដើរតាមពួកគេ « ពុំជឿដល់ការប្រែចិត្តពីអំពើបាបទាំងឡាយរបស់គេឡើយ » ( អាលម៉ា 15:15 ) ។

ដូចនៅក្នុងជំនាន់ នីហ៊រ និងកូរីហ៊រ ដែរ យើងរស់នៅក្នុងជំនាន់មួយ មិនយូរទេ ពីមុនការយាងមករបស់ព្រះយេស៊ូវគ្រីស្ទ---ក្នុងករណីរបស់យើង ជាពេលនៃការរៀបចំសម្រាប់ការយាងមកជាលើកទីពីររបស់ទ្រង់ ។ ហើយស្រដៀងគ្នាដែរ ជាញឹកញាប់ សារនៃការប្រែចិត្តមិនត្រូវបានស្វាគមន៍ទេ ។ អ្នកខ្លះប្រកាសថា បើសិនជាមានព្រះមែននោះ ទ្រង់នឹងមិនតម្រូវពីយើងឡើយ (សូមមើល អាលម៉ា 18:5 ) ។ សព្វថ្ងៃនេះ អ្នកផ្សេងដែលអះអាងថា ព្រះដែលពេញដោយក្តីស្រឡាញ់ អត់ទោសដល់បាបទាំងអស់ ដោយផ្អែកលើការសារភាពធម្មតាៗ ឬបើមានការដាក់ទណ្ឌកម្មមួយចំពោះអំពើបាប នោះ « ព្រះទ្រង់នឹងវាយយើងពីរបីរំពាត់ ហើយនៅទីបំផុត យើងក៏នឹងបានសង្គ្រោះនៅក្នុងនគរព្រះដែរ » ( នីហ្វៃទី2 28:8 ) ។ អ្នកផ្សេងទៀត ដូចកូរីហ៊រដែរ បដិសេដថា គ្មានព្រះគ្រីស្ទ និងគ្មានអំពើបាបទេ ។ គោលលទ្ធិរបស់គេគឺថា គុណតម្លៃ បទដ្ឋាន និងសូម្បីតែសេចក្តីពិតគឺទាក់ទងគ្នាទាំងអស់ ។ ទោះយ៉ាងណា ក៏ដោយអ្វី ដែលមនុស្សម្នាក់គិតថាត្រូវសម្រាប់គាត់ហើយ នោះមិនអាចត្រូវបានវិនិច្ឆ័យដោយអ្នកដទៃថា ខុស ឬមានបាបនោះឡើយ ។

ជាដំបូង ទស្សនៈបែបនោះហាក់គួរឲ្យចាប់អារម្មណ៍ ព្រោះវាអនុញ្ញាតឲ្យយើងផ្តេកផ្តួលតាមចំណង់ ឬបំណងណាក៏បានដោយមិនខ្វល់ពីលទ្ធ-ផល ។ ដោយការប្រើការបង្រៀនរបស់នីហ៊រ និងកូរីហ៊រ នោះយើងអាចផ្លាស់ប្តូរ និងធ្វើឲ្យអ្វីគ្រប់យ៉ាងសមហេតុផល ។ ពេលព្យាការីបានហៅឲ្យប្រែចិត្ត វា « ធ្វើឲ្យអ្នកមិនប្រែចិត្តខឹងសម្បា » ។ តែនៅក្នុងភាពពិតការហៅដែលទាយទុក គួរតែបានទទួលដោយអំណរ ។ បើគ្មានការប្រែចិត្ត នោះគ្មានការរីកចម្រើនពិត ឬ ការកែលំអរនៅក្នុងជីវិតឡើយ ។ ការមិនប្រកាន់ទោសពុំជួយដល់ការរីកចម្រើននោះទេ ។ ការធ្វើពើថា គ្មានអំពើបាប ពុំសម្រាលបន្ទុក និងការឈឺចាប់របស់វាទេ ។ ការរងទុក្ខដោយអំពើបាប ពុំបានផ្លាស់ប្តូរដោយខ្លួនវាឲ្យប្រសើរអ្វីសោះឡើយ ។ មានតែការប្រែចិត្តប៉ុណ្ណោះ ដែលនាំឲ្យមានជីវិតដ៏ប្រសើរមួយ ។ ហើយ ពិតណាស់ មានតែតាមរយៈការប្រែចិត្តប៉ុណ្ណោះ ដែលយើងអាចទទួលបាននូវក្តីមេត្តាដ៏ធួនរបស់ព្រះយេស៊ូវគ្រីស្ទ និងទទួលបានការសង្គ្រោះ ។ ការប្រែចិត្ត គឺជា អំណោយទានដ៏ទេវភាពមួយ ហើយនឹងមានស្នាមញញឹមលើមុខយើង ពេលយើងនិយាយពីវា ។ វាបង្ហាញយើងទៅកាន់សេរីភាព ទំនុកចិត្ត និង សេចក្តីសុខសាន្ត ។ អំណោយទាននៃការប្រែចិត្តជាបុព្វហេតុនៃការអបអរដ៏ពិត ពុំមែនជាអ្វីមួយដែលបញ្ចប់ការអបអរ និងនាំឲ្យមានទុក្ខព្រួយនោះទេ ។

ការប្រែចិត្តអាចកើតឡើងដោយសារដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទប៉ុណ្ណោះ ។ វាជាការលះបង់ដ៏អស្ចារ្យរបស់ទ្រង់ដែល « នាំមកនូវមធ្យោបាយទាំងឡាយដល់មនុស្ស ដើម្បីឲ្យគេមានសេចក្តីជំនឿ ចំពោះការប្រែចិត្ត » ( អាលម៉ា 34:15—16 ) ។ ការប្រែចិត្តជាលក្ខខណ្ឌចាំបាច់ ហើយក្តីករុណានៃព្រះគ្រីស្ទ ជាអំណាចដែល «សេចក្តីមេត្តាករុណាអាចធ្វើឲ្យស្កប់ស្កល់ដល់ការទាមទារនៃសេចក្តីយុត្តិធម៌ » (អាលម៉ា 34:16) ។ ទីបន្ទាល់របស់យើងគឺដូចនេះ ៖

« យើងដឹងថា ការរាប់ជាសុចរិត [ ឬការអត់ទោសពីបាប ] តាមរយៈព្រះគុណនៃព្រះអម្ចាស់ និងព្រះអង្គសង្គ្រោះដ៏ជាព្រះយេស៊ូវគ្រីស្ទនោះគឺយុត្តិធម៌ និងត្រឹមត្រូវ ។

« ហើយយើងក៏ដឹងដែរថា ការញែកជាបរិសុទ្ធ តាមរយៈព្រះគុណនៃព្រះអម្ចាស់ និងព្រះអង្គសង្គ្រោះ ដ៏ជាព្រះយេស៊ូវគ្រីស្ទនោះគឺយុត្តិធម៌ និងត្រឹមត្រូវ ចំពោះអស់អ្នកណាដែលស្រឡាញ់ ហើយបម្រើព្រះ ដោយអស់ពីពលំ អស់ពីគំនិត និងអស់ពីកម្លាំង » ( គ. និង ស. 20:30--31 ) ។

ការប្រែចិត្តជាប្រធានបទដ៏ធំមួយ តែថ្ងៃនេះ ខ្ញុំចង់លើកឡើងប្រាំផ្នែកនៃគោលការណ៍គ្រឹះនៃដំណឹងល្អនេះ ដែលខ្ញុំសង្ឃឹមថាមានប្រយោជន៍ ។

ទីមួយ ការអញ្ជើញឲ្យប្រែចិត្ត ជាការបង្ហាញក្ដីស្រឡាញ់ ។ ពេលព្រះអង្គសង្គ្រោះ « ចាប់តាំងប្រកាសដោយបន្ទូលថា ចូរប្រែចិត្តឡើង ត្បិតនគរស្ថានសួគ៌ជិតដល់ហើយ » ( ម៉ាថាយ 4:17 ) វាជាសារនៃក្ដីស្រឡាញ់ ជាការអញ្ជើញដល់អស់អ្នកដែលស័ក្តិសមចូលរួមនឹងទ្រង់ « ហើយមានសេចក្ដីអំណរចំពោះព្រះបន្ទូល អំពីជីវិតដ៏នៅអស់កល្បជានិច្ច នៅនាលោកីយនេះ និងជីវិតដ៏នៅអស់កល្បជានិច្ច នៅ ឯនាបរលោក គឺជាសិរីល្អដ៏នៅអតមៈ » (ម៉ូសេ 6:59)។

បើយើងមិនអញ្ជើញអ្នកផ្សេងឲ្យផ្លាស់ប្ដូរ ឬបើយើងពុំតម្រូវឲ្យខ្លួនឯងប្រែចិត្តទេ នោះយើងបរាជ័យក្នុងភារកិច្ចគ្រឹះ ដែលយើងមានចំពោះគ្នាទៅវិញទៅមក និងចំពោះខ្លួនឯង ។ ឪពុកម្ដាយដែលបណ្ដោយកូនឲ្យធ្វើបាប មិត្តភក្តិដែលផ្ដេកផ្ដោលតាមនោះ អ្នកដឹកនាំសាសនាចក្រដែលភ័យខ្លាច ក្នុងភាពពិត គឺខ្វល់ខ្វាយពីខ្លួនឯង ជាជាងសុខមាលភាព និងសុភមង្គលរបស់ពួកអ្នកដែលគេអាចជួយ ។ មែនហើយ ពេលខ្លះ ការហៅឲ្យប្រែចិត្តជាការដែលគួរឲ្យអន់ចិត្ត និងអាចជាការស្អប់ តែក្នុងភាពពិត បានដឹកនាំដោយព្រះវិញ្ញាណ វាជាទង្វើនៃការខ្វល់ខ្វាយដ៏ពិតប្រាកដ  (សូមមើល គ. និង ស. 121:43-44) ។

ទីពីរ ការប្រែចិត្តមានន័យថា ពុះពារដើម្បីផ្លាស់ប្ដូរ ។ វានឹងជាការចំអកដល់ការរងទុក្ខរបស់ព្រះអង្គសង្គ្រោះ នៅក្នុងសួនច្បារគេតសេម៉ានី និងនៅលើឈើឆ្កាងសម្រាប់យើង ត្បិតយើងរំពឹងថា ទ្រង់នឹងផ្លាស់ប្រែយើងទៅជាតួអង្គសុចរិត ដោយគ្មានការប្រឹងប្រែងដ៏ពិតណាសោះ ក្នុងផ្នែករបស់យើងនោះ ។ ផ្ទុយទៅវិញ យើងស្វែងរកក្ដីករុណាទ្រង់ ដើម្បីបំពេញ និងផ្ដល់រង្វាន់ដល់ការប្រឹងប្រែងដ៏ឧស្សាហ៍បំផុតរបស់យើង ( សូមមើល នីហ្វៃទី2 25:23 ) ។ ប្រហែល យើងគួរអធិស្ឋានដើម្បីមានពេលវេលា និងឱកាសដើម្បីធ្វើ និងព្យាយាម និងយកឈ្នះ ឲ្យបានច្រើនដូចជាយើងអធិស្ឋានសុំក្ដីករុណាដែរ ។

ប្រាកដណាស់ ព្រះអម្ចាស់ប្រទានពរដល់មនុស្សម្នាក់ ដែលមានបំណងមកកាន់ការជំនុំជំរះដោយស័ក្តិសម អ្នកដែលធ្វើការដោយការតាំងចិត្ត ពីមួយថ្ងៃទៅមួយថ្ងៃ ដើម្បីជំនួសភាពទន់ខ្សោយ ដោយភាពរឹងមាំវិញ ។ ការប្រែចិត្តពិត ការផ្លាស់ប្ដូរពិត អាចតម្រូវឲ្យមានការប៉ុនប៉ងម្ដងហើយម្ដងទៀត ប៉ុន្តែមានអ្វីមួយដែលស្អាតស្អំ និងបរិសុទ្ធ ក្នុងការពុះពារបែបនោះ ។ ការអត់ទោសដ៏ទេវភាព និងការព្យាបាលចូលមកដោយឯកឯងដល់ព្រលឹងមួយ ត្បិតជាការពិត « គុណធម៌ស្រឡាញ់គុណធម៌ ពន្លឺនៅជាប់នឹងពន្លឺ [និង] សេចក្ដីមេត្តាករុណាមានសេចក្ដីអាណិតដល់សេចក្ដីមេត្តាករុណា ហើយទទួលស្គាល់អ្វីដែលជារបស់ខ្លួន » ( គ. និង ស. 88:40 ) ។

ដោយការប្រែចិត្តយើងអាចអភិវឌ្ឍសមត្ថភាពយើងដោយខ្ជាប់ខ្ជួន ដើម្បីរស់នៅតាមច្បាប់សេឡេស្ទាល ត្បិតយើងដឹងថា « អ្នកណាដែលពុំអាចនៅជាប់ក្នុងក្រិត្យវិន័យនៃនគរសេឡេស្ទាលបានទេ នោះពុំអាចនៅជាប់ក្នុងសិរីល្អខាងសេឡេស្ទាលបានឡើយ » ( គ. និង ស. 88:22 ) ។

ទីបី ការប្រែចិត្តពុំមានន័យត្រឹមតែ លះបង់អំពើបាបប៉ុណ្ណោះទេ តែត្រូវតាំងចិត្តដើម្បីគោរពតាមផងដែរ ។ សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយពន្យល់ថា « ការប្រែចិត្តមានន័យថា ការបែរដួងចិត្ត និងឆន្ទៈទៅកាន់ព្រះ [ក៏ដូចជា] ជាការលះបង់ចោលអំពើបាប ដែលយើងទោរទន់ទៅរកដោយឯកឯងផងដែរ » ។[1] គំរូមួយអំពីការបង្រៀននេះ ពីព្រះគម្ពីរមរមនមានក្នុងពាក្យសម្ដីរបស់អាលម៉ា ទៅកាន់កូនគាត់ម្នាក់ថា ៖

« ឪពុកបញ្ជាដល់កូន ឱ កូនប្រុសរបស់ឪពុកអើយ ដោយកោតខ្លាចដល់ព្រះ ចូរកូនឈប់ធ្វើនូវអំពើទុច្ចរិតទាំងឡាយរបស់កូនទៅ ចូរកូនបែរទៅរកព្រះអម្ចាស់ ដោយអស់ពីដួងចិត្ត និងអស់សមត្ថភាព និងអស់កម្លាំងរបស់កូនចុះ  » ( អាលម៉ា 39:12--13, សូមមើលផងដែរ ម៉ូសាយ 7:33, នីហ្វៃទី3 20:26; មរមន 9:6 ) ។ ចំពោះការងាកទៅរកព្រះអម្ចាស់របស់យើងបានពេញលេញ នោះវាមិនត្រូវបញ្ចូលអ្វី ក្រៅតែពីសេចក្ដីសញ្ញាដើម្បីគោរពទ្រង់នោះទេ ។ ជាញឹកញាប់ យើងនិយាយពីសេចក្ដីសញ្ញា ជាសេចក្ដីសញ្ញានៃបុណ្យជ្រមុជទឹក ដោយវាត្រូវបានបង្ហាញ ដោយជ្រមុជទឹកនៅក្នុងទឹក ( សូមមើល ម៉ូសាយ 18:10 ) ។ បុណ្យជ្រមុជទឹកផ្ទាល់របស់ព្រះអង្គសង្គ្រោះបានផ្ដល់ជាគំរូ ដែលបានបញ្ជាក់ពីសេចក្ដីសញ្ញានៃការគោរពដល់ព្រះវរបិតា ។

« តែទោះបើទ្រង់បរិសុទ្ធក្ដី ក៏គង់តែទ្រង់បន្ទាបខ្លួនចំពោះព្រះវរបិតា ហើយធ្វើបន្ទាល់ដល់ព្រះវរបិតាថា ទ្រង់នឹងគោរពព្រះអង្គ ដោយកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់ព្រះអង្គ » ( នីហ្វៃទី2 31:7 ) ។ បើគ្មានសេចក្ដីសញ្ញានេះទេ ការប្រែចិត្តនៅតែមិនបានពេញលេញដដែល ហើយអំពើបាបពុំត្រូវបានអភ័យទោសឲ្យឡើយ ។[2] សាស្ត្រាចារ្យ ល្វាអេល វៃណ្វល បានបង្ហាញគំនិតដូចគ្នានេះ ក្នុងរបៀបមួយដ៏គួរឲ្យចងចាំថា « ជម្រើសដើម្បីប្រែចិត្តជាជម្រើសមួយ ដើម្បីផ្លាស់ប្ដូរគ្រប់ទិសដៅ [ ដោយតាំងចិត្ត ] ដើម្បីដើរតាមផ្លូវតែ*មួយ*ជានិច្ច ជាផ្លូវ*មួយ* ដែលនាំទៅជីវិតអស់កល្បជានិច្ច » ។[3]

ទីបួន ការប្រែចិត្តតម្រូវឲ្យមានគោលបំណងដ៏មុះមុត និងមានឆន្ទៈដើម្បីបន្តព្យាយាម ទោះជាឆ្លងកាត់ការឈឺចាប់ក៏ដោយ ។ ការព្យាយាមបង្កើតនូវបញ្ជីមួយ អំពីជំហានជាក់លាក់នៃការប្រែចិត្ត អាចជាប្រយោជន៍ដល់មនុស្សមួយចំនួន តែវាក៏អាចនាំទៅរកវិធីមួយដែលពុំមានការគិតក្នុងការប្រែចិត្ត ដែលគ្រាន់តែជាបញ្ជីមួយនៃជំហានទាំងឡាយ ដើម្បីធ្វើប៉ុណ្ណោះ តែគ្មានពុំមានអារម្មណ៍ ឬការផ្លាស់ប្ដូរដ៏ពិតឡើយ ។ ការប្រែចិត្តដ៏ពិតគឺមិនស្មាក់ស្មើរទេ ។ ព្រះអម្ចាស់ផ្ដល់ការតម្រូវគ្រឹះពីរគឺ ៖ « តាមរបៀបនេះ អ្នករាល់គ្នាអាចដឹងបើសិនជាមនុស្សណាម្នាក់ប្រែចិត្តពីអំពើបាបទាំងឡាយរបស់ខ្លួនមែន ឬអត់---មើលចុះ អ្នកនោះនឹងសារភាពអំពីអំពើបាបទាំងឡាយ ហើយលះបង់អំពើបាបទាំងនោះ » ( គ. និង ស. 58:43 ) ។

ការសារភាព និងការលះបង់ជាគោលការណ៍ដ៏មានឥទ្ធិពល ។ វាលើលពីការដែលគ្រាន់តែនិយាយដោយធម្មតាថា « ខ្ញុំព្រមទទួល ខ្ញុំសូមទោស » ។ វាជាការទទួលស្គាល់ដ៏ជ្រាលជ្រៅ និងជូនកាលដ៏ឈឺចាប់ ចំពោះកំហុស និងការធ្វើឲ្យអាក់អន់ចិត្ត ដល់ព្រះ និងមនុស្ស ។ ជាញឹកញាប់ ទុក្ខព្រួយ និងការសោកស្ដាយ និងទឹកភ្នែកដ៏ល្វីងជូចត់ កើតឡើងជាមួយនឹងការសារភាព ជាពិសេស ពេលទង្វើគាត់ជាបុព្វហេតុនៃការឈឺចាប់ដល់ជនណាម្នាក់ ឬកាន់តែអាក្រក់ទៀត បើបានដឹកនាំនរណាម្នាក់ឲ្យធ្វើបាប ដូចអាលម៉ាបានធ្វើដែរ គឺទូលថា « ឱព្រះយេស៊ូវអើយ ព្រះអង្គជាព្រះរាជបុត្រានៃព្រះ សូមព្រះអង្គមានសេចក្ដីមេត្តាករុណាមកលើទូលបង្គំផង ដែលជាអ្នកនៅក្នុងប្រមាត់ល្វីងជូរចត់ ហើយកំពុងតែឡោមព័ទ្ធទៅដោយច្រវាក់ដ៏អស់កល្បជានិច្ចនៃសេចក្ដីស្លាប់ » ( អាលម៉ា 36:18 ) ។

ដោយសារជំនឿលើព្រះប្រោសលោះ និងព្រះចេស្ដាទ្រង់ ដែលពេញដោយក្ដីមេត្តា នោះការអស់សង្ឃឹមប្រែទៅជាមានសង្ឃឹម ។ ធម្មជាតិ និងបំណងរបស់មនុស្សម្នាក់ផ្លាស់ប្ដូរ ហើយអំពើបាបដែលធ្លាប់ចង់ធ្វើក៏ក្លាយជាគួរឲ្យស្អប់ខ្ពើមជាខ្លាំង ។ ការប្ដេជ្ញាចិត្តដើម្បីលះបង់បាប និងដើម្បីកែប្រែ ឲ្យបានល្អបំផុតតាមដែលអាចធ្វើបាន នូវការខូចខាតដែលគាត់បានបង្កនោះនឹងលូតលាស់ឡើងក្នុងដួងចិត្តថ្មីនោះ ។ មិនយូរទេ ការតាំងចិត្តនេះ លូតលាស់ទៅជាសេចក្ដីសញ្ញានៃការគោរពចំពោះព្រះ ។ បន្ទាប់ពីធ្វើសេចក្ដីសញ្ញានោះហើយ ព្រះវិញ្ញាណបរិសុទ្ធ ជាទូតនៃក្ដីមេត្តានៃព្រះ នឹងនាំមកនូវការរំដោះ និងការអត់ទោស ។ មនុស្សម្នាក់ត្រូវបានបំផុសឲ្យប្រកាសនូវអ្វីដែលអាលម៉ាបានប្រកាស ថា « ហើយ ឱសេចក្ដីអំណរ និងរស្មីដ៏អស្ចារ្យ ដែលឪពុក [ ពិតជា ] បានឃើញ មែនហើយ ព្រលឹងឪពុកបានពោរពេញទៅដោយសេចក្ដីអំណរ លើសជាងការឈឺចាប់របស់ឪពុកទៅទៀត ! » ( អាលម៉ា 36:20 ) ។

ការឈឺចាប់ដែលតម្រូវឲ្យមានសម្រាប់ការប្រែចិត្ត តែងតែឈឺចាប់តិចជាងខ្លាំងណាស់ បើធៀបទៅនឹងការរងទុក្ខដែលតម្រូវដើម្បីស្កប់ស្កល់ដល់សេចក្ដីយុត្តិធម៌ សម្រាប់អំពើបាបដែលមិនបានប្រែចិត្ត ។ ព្រះអង្គសង្គ្រោះពុំបានមានបន្ទូលច្រើនពីអ្វីដែលទ្រង់បានស៊ូទ្រាំ ដើម្បីឲ្យស្កប់ស្កល់ដល់ការទាមទារនៃសេចក្ដីយុត្តិធម៌ និងការធ្វើឲ្យធួនសម្រាប់បាបរបស់យើងឡើយ តែទ្រង់ពិតជាបានបើកបង្ហាញថា ៖ « ត្បិតមើលចុះ យើងជាព្រះ បានរងទុក្ខនូវការទាំងនេះ ជំនួសមនុស្សទាំងអស់ ដើម្បីកុំឲ្យគេអាចរងទុក្ខ បើសិនជាពួកគេប្រែចិត្ត ។

« ប៉ុន្តែ បើសិនជាពួកគេមិនព្រមប្រែចិត្តទេ នោះពួកគេត្រូវរងទុក្ខ ដូចជាយើងដែរ ។

« គឺជាសេចក្ដីរងទុក្ខវេទនា ដែលបណ្ដាលឲ្យយើង គឺជាព្រះដែលមហិមាលើអ្វីៗទាំងអស់ត្រូវញ័រដោយសារតែការឈឺចាប់ ហើយត្រូវច្រូចលោ-ហិតចេញពីគ្រប់រន្ធញើស ហើយត្រូវរងទុក្ខព្រមទាំងរូបកាយ និងវិញ្ញា-ណផង---ហើយដើម្បីកុំឲ្យយើងត្រូវផឹកពែងល្វីង » ( គ. និង ស. 19:16--18 ) ។

ទីប្រាំ មិនថាការប្រែចិត្តឈឺចាប់យ៉ាងណាទេ វាត្រូវបានលេបក្នុងសេចក្ដីអំណរនៃការអត់ទោស ។ ក្នុងសន្និសិទទូទៅដែលមានចំណងជើងថា « ព្រលឹមដ៏អស្ចារ្យនៃការអត់ទោស » ប្រធាន ប៊យដ៍ ឃេ ផាកកឺ បានថ្លែងស្រដៀងគ្នានេះថា ៖

« ក្នុងខែ មេសា ឆ្នាំ 1847 ព្រិកហាំ យ៉ង់ បានដឹកនាំក្រុមត្រួសត្រាយផ្លូវទីមួយ ចេញពី Winter Quarters ។ នៅពេលនោះដែរ ប្រមាណ 2,500 គីឡូម៉ែត្រទៅទិសខាងលិច អ្នកនៅរស់របស់ក្រុម ដូណឺរ បានជួបការលំបាកពេលចុះជម្រាលភ្នំ ស៊ីរ៉ា ណេវ៉ាដា ទៅក្នុងជ្រលងសាក្រាម៉ង់តូ ។

« ពួកគេបានជាប់នៅទីនោះក្នុងរដូវរងាដ៏ត្រជាក់បំផុត ដោយជាប់ក្នុងពំនូកព្រិល ពីខាងក្រោមកំពូលដែលខ្ពស់បំផុត ។ វាស្ទើរតែមិនអាចជឿបាន ថាអាចមាននរណាម្នាក់នៅរស់រានបាន រាប់ថ្ងៃ រាប់សប្ដាហ៍ និងរាប់ខែ ដោយអត់អាហារ និងការរងទុក្ខដែលមិនអាចពណ៌នាបាន ។ ក្នុងចំណោមអ្នករស់រានទាំងនោះ មានក្មេងប្រុសអាយុ 15 ឆ្នាំម្នាក់ឈ្មោះ ចន ប្រ៊ីន ។ នាយប់ថ្ងៃទី 24 ខែមេសា គេបានដើរទៅក្នុងវាលចិញ្ចឹមសត្វ ចនសិន ។ ជាច្រើនឆ្នាំក្រោយមក ចន បានសរសេរថា ៖

« ‹ ក្រោយពេលថ្ងៃលិចយ៉ាងយូរ ទើបយើងទៅដល់វាលចិញ្ចឹមសត្វ ចសិន ដូច្នេះពេលខ្ញុំបានឃើញកន្លែងនោះជាលើកដំបូង គឺវាព្រលឹមស្រាងៗទៅហើយ ។ អាកាសធាតុល្អ ទីវាលគ្របដណ្ដប់ដោយស្មៅបៃតង បក្សាបក្សីកំពុងច្រៀងពីចុងឈើ ហើយការធ្វើដំណើរបានចប់ហើយ ។ ខ្ញុំស្ទើរតែមិនជឿថា ខ្ញុំនៅរស់ ។ ‹ ទិដ្ឋភាពដែលខ្ញុំបានឃើញនាព្រឹកនោះ ហាក់ថតជាប់ក្នុងគំនិតខ្ញុំ ។ ហេតុការណ៍ច្រើនបំផុតបានចេញពីការចងចាំ តែខ្ញុំតែងឃើញជំរុំដែលនៅជិតវាលចិញ្ចឹមសត្វ ចនសិន ជានិច្ច › ។ ពីដំបូង ខ្ញុំភាន់ច្រឡំ ដោយការថ្លែងរបស់គាត់ដែលថា ‹ ហេតុការណ៍ច្រើនបំផុតបានចេញពីការចងចាំ › ។ តើការរងទុក្ខដែលមិនអាចពណ៌នាបានជាច្រើនខែ អាចចេញពីគំនិតគាត់យ៉ាងណាទៅ ? តើរដូវរងាដ៏ងងឹត និងឃោរឃៅនោះ អាចជំនួសដោយព្រឹកដ៏អស្ចារ្យមួយ ដោយរបៀបណា ?

« បន្ទាប់ពីខ្ញុំបានគិតថែមទៀត ខ្ញុំឃើញថា វាមិនមានអ្វីដែលភាន់ច្រឡំទៀតសោះ ។ ខ្ញុំបានឃើញអ្វីមួយស្រដៀងគ្នានេះ កើតឡើងដល់មនុស្សដែលខ្ញុំស្គាល់ ។ ខ្ញុំបានឃើញមនុស្សម្នាក់ ដែលបាននៅក្នុងរដូវរងានៃកំហុស និងការអត់ឃ្លានខាងវិញ្ញាណដ៏យូរ បានងើបឡើងក្នុងព្រឹកព្រលឹមនៃការអត់ទោស ។

« ពេលព្រឹកមកដល់ ពួកគេបានរៀនការណ៍នេះ ៖

« ‹ មើលចុះ អ្នកណាដែលប្រែចិត្តពីអំពើបាបទាំងឡាយរបស់ខ្លួន អ្នកនោះឈ្មោះថាបានអត់ទោសឲ្យហើយ ហើយយើងជាព្រះអម្ចាស់ មិនចាំពីអំពើបាបទាំងនោះទៀតទេ › [ គ. និង ស. 58:42 ] » ។[4]

ខ្ញុំទទួលស្គាល់ និងថ្លែងទីបន្ទាល់ដោយអំណរគុណថា ការរងទុក្ខដែលពុំអាចយល់បាន ការស្លាប់ និងការរស់ឡើងវិញនៃព្រះអម្ចាស់យើង « នាំមកនូវលក្ខខ័ណ្ឌនៃការប្រែចិត្ត » ( ហេលេមិន 14:18 ) ។ អំណោយទានដ៏ទេវភាពនៃការប្រែចិត្តជាកូនសោចូលទៅកាន់សុភមង្គល ទាំងក្នុងជីវិតនេះ និងជីវិតបន្ទាប់ ។ ដោយនូវបន្ទូលព្រះអង្គសង្គ្រោះ និងក្នុងការបន្ទាបខ្លួនដ៏ជ្រាលជ្រៅ និងដោយក្ដីស្រឡាញ់ ខ្ញុំអញ្ជើញអ្នកទាំងអស់គ្នា « ចូរប្រែចិត្តឡើង ត្បិតនគរស្ថានសួគ៌ជិតដល់ហើយ » ( ម៉ាថាយ 4:17 ) ។ ខ្ញុំដឹងថា ដោយការទទួលយកការអញ្ជើញនេះ អ្នកនឹងរកឃើញក្ដីអំណរ ទាំងឥឡូវនេះ និងរហូតទៅ ។ ក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ

1. សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ « ការប្រែចិត្ត » ។

2. ព្រះគម្ពីរមរមនលើកឡើងជាច្រើនដងពីការ « ទទួលបុណ្យជ្រមុជទឹកចំពោះការប្រែចិត្ត » ( សូមមើល ម៉ូសាយ 26:22; អាលម៉ា 5:62; 6:2; 7:14; 8:10; 9:27; 48:19; 49:30; ហេលេមិន 3:24; 5:17, 19; នីហ្វៃទី3 1:23; 7:24--26; មរ៉ូណៃ 8:11 ) ។ យ៉ូហានបាទីស្ទ បានប្រើពាក្យដូចគ្នានេះដែល ( សូមមើល ម៉ាថាយ 3:11 ) ហើយប៉ុល បាននិយាយពីការ « ធ្វើបុណ្យជ្រមុជទឹក ពីដំណើរការប្រែចិត្ត » ( កិច្ចការ 19:4 ) ។ ឃ្លានេះក៏មាននៅក្នុង គោលលទ្ធិ និងសេចក្ដីសញ្ញា ផងដែរ ( សូមមើល គ. និង ស. 35:5; 107:20 ) ។ « បុណ្យជ្រមុជទឹកពី ឬចំពោះការប្រែចិត្ត » សំដៅលើការពិតថា បុណ្យជ្រមុជទឹកជាមួយនឹងសេចក្ដីសញ្ញានៃការគោរព ជាជំហានចុងក្រោយនៃការប្រែចិត្ត ។ ដោយការប្រែចិត្តពេញលេញ រួមទាំងបុណ្យជ្រមុជទឹក នោះមនុស្សម្នាក់សមនឹងទទួលការដាក់ដៃលើក្បាលដើម្បីទទួលអំណោយទានព្រះវិញ្ញាណបរិសុទ្ធ ហើយដោយអំណោយទានព្រះវិញ្ញាណបរិសុទ្ធ ដែលមនុស្សម្នាក់ទទួលបុណ្យជ្រមុជដោយព្រះវិញ្ញាណ ( សូមមើល យ៉ូហាន 3:5 ) និងការអត់ទោសពីអំពើបាបទាំងឡាយ ៖ « ត្បិតទ្វារដែលអ្នករាល់គ្នាត្រូវចូលនោះគឺជាការប្រែចិត្ត និងបុណ្យជ្រមុជដោយទឹក ហើយបន្ទាប់មក គឺការផ្ដាច់បាបទាំងឡាយរបស់អ្នកដោយភ្លើង និងដោយព្រះវិញ្ញាណបរិសុទ្ធ » ( នីហ្វៃទី2 31:17 ) ។

3. Noel B. Reynolds, « The True Points of My Doctrine,» *Journal of Book of Mormon Studies* វ៉ុល. 5, no. 2 ( សរទរដូវ ឆ្នាំ 1996): 35, គូសបញ្ជាក់បន្ថែម ។

4. Boyd K. Packer « The Brilliant Morning of Forgiveness» *Ensign* ខែវិច្ឆិកា 1995 ទំព័រ 18 ។